# ២២- រឿង អណ្ដើកនិងស្វា

មានរឿងនិទានមួយថា អណ្ដើក និងស្វា វាសុំធ្វើជន្លងគ្នា តែគ្មានកូនចៅទៅចងពន្ធអ្វីទេ គ្រាន់តែនិយាយថា សុំគ្នាធ្វើជន្លង ។ សត្វទាំងពីរ ស្រឡាញ់រាប់អានគ្នា ដូចជន្លងអ្នកទាំងពួងនោះដែរ ។ លុះចំណេរយូរទៅ ជន្លងខាងស្វានោះ គេមានកូនត្រូវរៀបការ គេហៅភ្ញៀវពួកស្វា សន្មតថ្ងៃនឹងស៊ីការ ទើបនឹកឃើញអណ្ដើកជាជន្លងថា « យើងការកូននេះ ហៅភ្ញៀវអស់ហើយ នៅតែអណ្ដើកជាជន្លង មិនទាន់បានទៅប្រាប់ឥឡូវ ជិតថ្ងៃការណាស់ទៅហើយ បើដូច្នោះឲ្យបម្រើទៅអញ្ជើញគាត់ផង បំណាច់យើងរាប់អានគ្នា យូរឆ្នាំណាស់មកហើយ » គិតហើយក៏ចាត់បម្រើឲ្យទៅអញ្ជើញ ។ ថ្ងៃដែលគេប្រជុំញាតិស៊ីការនោះ អណ្ដើកក៏ទៅដល់ដែរ តែនឹងឡើងទៅស៊ីផឹកនឹងគេមិនរួច ។ ពួកស្វាបានឃើញ ក៏ទៅប្រាប់ជន្លងស្វាថា « ត្បិតជន្លងអណ្ដើកមកដល់ហើយ នៅឯក្រោមដើមឈើ » ។ ជន្លងស្វាចុះមក ឃើញអណ្ដើកក៏ប្រាប់ថាជន្លងឯងឡើងមិនរួចនឹងគេ មានតែជន្លងឯងខាំវល្លិនេះចុះ យើងនឹងស្រាវឡើង ប៉ុន្តែបើមិនទាន់ដល់ទៅកន្លែងដែលយើងអង្គុយទេ ជន្លងឯងកុំនិយាយឲ្យសោះ ទោះបីឃើញអ្វី ឬគេថាអ្វីក៏ដោយ, តែនិយាយធ្លាក់មកស្លាប់ហើយ ។ អណ្ដើកទទួលបណ្ដាំជន្លងនោះសព្វគ្រប់ហើយ ក៏ទទួលខាំវល្លិ ។ ពួកស្វាទាំងប៉ុន្មាន ក៏ស្រាវវល្លិនោះឡើង នាំអណ្ដើកទៅឯថ្នាក់លើ ។

លុះទៅជិតដល់កន្លែង ដែលគេនឹងដាក់នោះ ជួនជាជន្លងស្រីស្វា ឃើញអណ្ដើក ក៏សួរដោយរាប់អានថា « ជន្លង ! សុខសប្បាយទេឬ ? » ។ អណ្ដើកភ្លេចពាក្យបណ្ដាំ ហាមាត់ស្ដីទៅនឹងជន្លង ក៏របូតមាត់ ធ្លាក់ខ្លួនដល់ដីបែកស្នូកដូចគេបោកនឹងថ្ម ស្លាប់នៅវេលានោះ ខានស៊ីការនោះទៅ ។

**មាត់អណ្ដើក។**